# លំហាត់អនុវត្ត

ក. ចូរអានអត្ថបទខាងក្រោមរួចឆ្លើយនឹងសំណួរ ។

ម្ដាយខ្ញុំឈ្មោះគន្ធា គាត់មានអាយុសាមសិបប្រាំបីឆ្នាំហើយ ។ សព្វថ្ងៃគ្រួសារខ្ញុំរស់នៅភូមិត្រពាំងត្របែក ឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ ។

ម្ដាយខ្ញុំមានមាឌធំល្មម កម្ពស់ប្រហែលមួយម៉ែត្រហុបសិប សម្បុរខ្មៅស្រអែម សក់វែងស្លូតច្រមុះស្រួច ភ្នែកធំល្មម ដៃជើងសមនឹងដងខ្លួន ។ គាត់និយាយស្ដីមួយៗ តែច្បាស់ ។ នៅពេលមានបុណ្យទានម្ដងៗ គាត់ស្លៀកពាក់ ផាមួង អាវប៉ាក់យ៉ាងស្អាត ។ ម្ដាយខ្ញុំឧស្សាហ៍ធ្វើការងារណាស់។ គាត់ជាអ្នករួសរាយ រាក់ទាក់ចំពោះមនុស្សទូទៅ ។ គាត់ចូលចិត្តនិយាយដាស់តឿនកូនចៅ ឱ្យខិតខំរៀនសូត្រ ។

ខ្ញុំគោរព និងស្រឡាញ់ម្ដាយខ្ញុំណាស់ ព្រោះគាត់ជាអ្នកមានគុណ បានបង្កើត បីបាច់ ថែរក្សាចិញ្ចឹមខ្ញុំ និងក្រុមគ្រួសារ ។

- គូសសញ្ញា ✓ ក្នុងប្រអប់ ☐ ចម្លើយដែលត្រឹមត្រូវ ។

១. តើអត្ថបទនេះពណ៌នាពីអ្វី ?

☐ ក. អំពីសិល្បៈតន្ត្រី ☐ ខ. អំពីរុក្ខជាតិ

☐ គ. អំពីសត្វ ☐ ឃ. អំពីមនុស្ស

២. តើម្ដាយគាត់ឈ្មោះអ្វី ? តើម្ដាយគាត់មានអាយុប៉ុន្មានឆ្នាំ ?

☐ ក. ឈ្មោះ សុភាព អាយុ សាមសិបឆ្នាំ ☐ ខ. ឈ្មោះ គន្ធា អាយុ សាមសិបប្រាំបីឆ្នាំ

☐ គ. ឈ្មោះ សុភី អាយុ សាមសិបពីរឆ្នាំ ☐ ឃ. ឈ្មោះ កញ្ញា អាយុ សាមសិបប្រាំឆ្នាំ

៣.តើសព្វថ្ងៃគាត់រស់នៅស្រុក ខេត្តណា ?

☐ ក. ស្រុកត្រាំកក់ ខេត្តតាកែវ ☐ ខ. ស្រុកត្រាំកក់ ខេត្តកំពង់ស្ពឺ

☐ គ. ស្រុកត្រាំកក់ ខេត្តកណ្ដាល ☐ ឃ. ស្រុកត្រាំកក់ ខេត្តកំពត

៤. តើម្ដាយរបស់គាត់មានមាឌ និងកម្ពស់ដូចម្ដេច?

☐ ក. មាឌតូច កម្ពស់មួយម៉ែត្រហាសិប ☐ ខ. មាឌធំ កម្ពស់មួយម៉ែត្រហាសិបបី

☐ គ. មាឌធំល្មម កម្ពស់មួយម៉ែត្រហុកសិប ☐ ឃ. មាឌធំ កម្ពស់មួយម៉ែត្រហុកសិបប្រាំ

៥. តើម្ដាយគាត់ជាមនុស្សដូចម្ដេច ?

☐ ក. ឧស្សាហ៍ រួសរាយ រាក់ទាក់ ☐ ខ. សុភាព មិនសូវមាត់ក

☐ គ. មុឹងម៉ាត់ ☐ ឃ. ខ្ជិល មិនសូវរួសរាយ រាក់ទាក់

LIVEWORKSHEETS

សំណេរ

១. ចូរពន្យល់ពាក្យខាងក្រោមឱ្យបានត្រឹមត្រូវ ។

- ឧស្សាហ៍ ( )..........................................................................................................។

- រួសរាយ ( )........................................................................................................។

- ថៃរក្សា ( )........................................................................................................។

២. ចូរគូសភ្ជាប់ពាក្យបដិសព្ទខាងក្រោមឱ្យបានត្រឹមត្រូវ។

| | |
|---|---|
| ក. ស្លូត | ១. ត្រឹមត្រូវ |
| ខ. ខ្ពស់ | ២. ស |
| គ. ខ្មៅ | ៣. កាច |
| ឃ. វែង | ៤. ស្អប់ |
| ង. ធំ | ៥. ទាប |
| ច. ស្រួច | ៦. ខ្លី |
| ឆ. ស្រឡាញ់ | ៧. តូច |
| ជ. ផ្តេសផ្តាស | ៨. ទាល |

៣. ចូរជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញវគ្គចម្រៀងខាងក្រោម។

| ខិតខំ | រាជការ | ទ្វេហារ | នឿយហត់ | ទ្រាំអត់ | គោរព | គុណ | សមុទ្រ |
|---|---|---|---|---|---|---|---|

ពុកម៉ែខ្ញុំ.............ធ្វើការ ទាំង.............ពុំដែលត្អូញត្អែរ

ការងារ.............ចម្ការស្រែ ធ្វើហូរហែពុំខ្លាច..............

បន្ទរះ មែនហើយពុំខ្លាចនឿយហត់ ។

ខ្ញុំស្រឡាញ់............លោកណាស់ ព្រោះលោកចាស់ពូកែ............

..............ធំធេងគ្មានដែនកំណត់ ទោះ..........ក៏ប្រៀបពុំបាន

បន្ទរះ មែនហើយក៏ប្រៀបពុំបាន ។

LIVEWORKSHEETS